ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៤៤៧ . ១៧៥ ឧរថ. អប

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩

# អាជ្ញាប័ណ្ណស្វែងរុករក

( លើកទី២)

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និង ការធ្វើអាជីវកម្មរ៉ែលោហធាតុនៅតំបន់អូរខ្វារ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងក្រុមហ៊ុន Oxiana (Cambodia) Limited and Shin Ha Mining Company Limited ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករកលេខ ២០៥ ឧរថ.ធរ.អប ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតស្នើសុំពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ របស់ក្រុមហ៊ុន Oxiana (Cambodia) Limited ។
- បានឃើញលិខិតស្នើសុំប្រគល់ផ្ទៃក្រឡាដីសម្បទានសិក្សាស្រាវជ្រាវរ៉ែលោហធាតុនៅតំបន់អូរខ្វារ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ចំនួន១០% ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ របស់ក្រុមហ៊ុន Oxiana (Cambodia) Limited ។

## សំរេច

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុន Oxiana (Cambodia) Limited and Shin Ha Mining Company Limited មានអាសយដ្ឋានផ្ទះលេខ ៤២, ផ្លូវលេខ២៤០, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហធាតុបន្តនៅតំបន់អូរខ្វារ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ ១៩២ (មួយរយកៅសិបពីរ) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោនេណា | ចំណុច | អាប់ស៊ីស | អ័រដោនេណា |
|---|---|---|---|---|---|
| A’ | 6 95000 E | 14 05700 N | G’ | 6 99500 E | 13 94000 N |
| B’ | 7 00000 E | 14 05700 N | H’ | 6 80000 E | 13 94000 N |
| C’ | 7 00000 E | 14 03000 N | I’ | 6 80000 E | 14 01000 N |
| D’ | 7 02000 E | 14 03000 N | J’ | 6 86000 E | 14 01000 N |
| E’ | 7 02000 E | 13 97000 N | K’ | 6 86000 E | 14 03000 N |
| F’ | 6 99500 E | 13 97000 N | L’ | 6 95000 E | 14 03000 N |

ប្រការ២: ក្រុមហ៊ុន Oxiana (Cambodia) Limited and Shin Ha Mining Company Limited ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

ប្រការ៣: អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១១។ មុនផុតកំណត់៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

ប្រការ៤: ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

ប្រការ៥: អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តមណ្ឌលគិរី និងប្រធានក្រុមហ៊ុន Oxiana (Cambodia) Limited and Shin Ha Mining Company Limited ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀងៗខ្លួន។

ប្រការ៦: អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩ តទៅ ។

ស៊ុយ_សែម

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងបរិស្ថាន
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកកែវសីមា
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ